អង្គភាពសវនកម្មផ្ទៃក្នុង

# អត្ថបទប្រចាំខែ

លេខ ២២/២៣ ចេញផ្សាយ ខែតុលា ឆ្នាំ២០២៣

# ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការគ្រប់គ្រងប្រតិបត្តិការ

ការតាមដានត្រួតពិនិត្យ និងវាយតម្លៃដើរតួយ៉ាងសំខាន់នៅក្នុងកិច្ចប្រតិបត្តិការនានារបស់ស្ថាប័ន និងដើម្បីធានាថាស្ថាប័ននោះបានអនុវត្តការងារស្របទៅតាមផែនការដែលបានកំណត់។

ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ជួយឱ្យស្ថាប័នអនុវត្តកិច្ចការនានាប្រកបទៅដោយប្រសិទ្ធភាព ប្រសិទ្ធផល និងភាពសន្សំសំចៃផងដែរ។ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃគឺជាដំណើរការនៃការប្រមូលព័ត៌មានជាបន្តបន្ទាប់ ដើម្បីធ្វើការវាយតម្លៃក្នុងគោលបំណង កំណត់ថាតើវឌ្ឍនភាពរបស់កិច្ចការងារនោះបាននឹងកំពុងឆ្ពោះទៅរកគោលដៅ គោលបំណងដែលបានកំណត់ទុកជាមុន ព្រមទាំងបញ្ជាក់អំពីផលប៉ះពាល់នានាដែលបង្កឡើងដោយការអនុវត្តសកម្មភាពការងារ។



## ១. យន្តការនៃការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

យន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃ គឺជាឧបករណ៍វាស់វែងនូវវឌ្ឍនភាពការងារ ឆ្ពោះទៅរកការសម្រេចគោលបំណង និងគោលដៅរបស់ស្ថាប័នដែលបានកំណត់ ដូចជាសូចនាករប្រចាំខែ សូចនាករប្រចាំត្រីមាសសូចនាករប្រចាំឆ្នាំ និងលទ្ធផលប្រចាំឆ្នាំ។ យន្តការនេះ តម្រូវឱ្យស្ថាប័នកំណត់នូវគោលដៅសម្រាប់សូចនាករនីមួយៗ ស្របតាមបេសកកម្ម ចក្ខុវិស័យ និងផែនការយុទ្ធសាស្ត្ររបស់ស្ថាប័ន ដើម្បីធានានូវប្រសិទ្ធភាពក្នុងភាពអាចវាស់វែងបានក្នុការអនុវត្ត និងជាមូលដ្ឋានសម្រាប់ថ្នាក់ដឹកនាំ ធ្វើការវាយតម្លៃលើវឌ្ឍនភាពការងារទាក់ទងនឹងគោលដៅដែលបានកំណត់ក្នុងផែនការ។

### ១.១. ការតាមដានត្រួតពិនិត្យ

ការតាមដានត្រួតពិនិត្យការងារ សំដៅទៅលើដំណើរការនៃការប្រមូល ការវិភាគ និងការវាយតម្លៃព័ត៌មាននៃការអនុវត្តការងារជាទៀងទាត់ដើម្បីធ្វើការសម្រេចចិត្តបានទាន់ពេលវេលា និងសមស្រប ហើយធានាបានថាការងារត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព គោលបំណងក្នុងការត្រួតពិនិត្យ គឺដើម្បីវាស់វែងការរីកចម្រើន និងការផ្លាស់ប្តូរនៅក្នុងស្ថានការណ៍ ឬសកម្មភាពដើម្បីពិនិត្យមើលថា តើការអនុវត្តការងារគឺស្របទៅតាមផែនការដែលបានកំណត់ដែរឬទេ ។

### ១. ២. ការវាយតម្លៃ

ការវាយតម្លៃ គឺជាប្រព័ន្ធនៃការប្រមូល និងវិភាគទិន្នន័យដើម្បីវាយតម្លៃពីភាពខ្លាំង និងភាពខ្សោយនៃការអនុវត្តផែនការរួចធ្វើការកែលម្អឱ្យមានប្រសិទ្ធភាព។ ជាទូទៅការវាយតម្លៃ ត្រូវបានធ្វើការឡើងនៅពេលបញ្ចប់ការអនុវត្តសកម្មភាពដោយថ្នាក់ដឹកនាំ ហើយការវាយតម្លៃនេះផងដែរក៏អាចធ្វើឡើងនៅពាក់កណ្តាលការអនុវត្តសកម្មភាពផងដែរ។



### ២. ការកែលម្អ

ដើម្បីធានាបានថា ប្រតិបត្តិការរបស់ស្ថាប័នដំណើរការទៅដោយរលូន លុះត្រាតែស្ថាប័នមានការកែលម្អទៅលើប្រតិបត្តិការរបស់ខ្លួនឱ្យស្របទៅតាមស្ថានភាពបច្ចុប្បន្ន។ ការកែលម្អគឺជាការធ្វើឱ្យអ្វីៗកាន់តែប្រសើរឡើង ដោយប្រើប្រាស់មូលដ្ឋាន បទពិសោធន៍ដែលធ្លាប់បានអនុវត្ត ដើម្បីជាមេរៀនក្នុងការកែលម្អ។ ការកែលម្អ គឺត្រូវធ្វើឡើងមិនត្រឹមតែធ្វើឱ្យល្អប្រសើរនោះទេ ព្រមទាំងទប់ស្កាត់បញ្ហាដែលកើតឡើងសារជាថ្មីម្តងទៀត។



### ៣. សមាសធាតុសំខាន់ៗសម្រាប់យន្តការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

សមាសធាតុសំខាន់ៗសម្រាប់យន្តការតាមដានត្រួតពិនិត្យ និងការវាយតម្លៃរួមមាន÷ របាយការណ៍ច្បាស់លាស់ពាក់ព័ន្ធនឹងការគ្រប់គ្រងប្រតិបត្តិការ, យន្តការនៃការប្រមូលទិន្នន័យដែលជួយក្នុងការពិនិត្យវឌ្ឍនភាព រួមទាំងជាមូលដ្ឋាន និងមធ្យោបាយដើម្បីប្រៀបធៀបវឌ្ឍនភាព និងសមិទ្ធផលទៅនឹងគោលដៅដែលបានគ្រោងទុក, មូលដ្ឋានគ្រឹះនៃការប្រមូលទិន្នន័យដោយមានក្របខ័ណ្ឌនៃការវាយតម្លៃ, យន្តការច្បាស់លាស់សម្រាប់ការរាយការណ៍ និងការប្រើប្រាស់នូវលទ្ធផលដែលបានពីការតាមដានត្រួតពិនិត្យ និងការវាយតម្លៃក្នុងការធ្វើការសម្រេចចិត្ត, និងការរៀបចំផែនការប្រកបដោយចីរភាពដោយពឹងផ្អែកទៅលើទិន្នន័យ ការគ្រប់គ្រង ការវិភាគ និងការរាយការណ៍ជាក់លាក់។

**អត្ថបទ÷** លោក **សុទ្ធ សេងធី**

**ឯកសារយោង÷**

ឧត្តមានុវត្តន៍នៃការគ្រប់គ្រងប្រតិបត្តិការរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.**

អត្ថបទអប់រំខ្លីៗស្តីពីសវនកម្មត្រូវបានរៀបរៀងដោយមន្ត្រីរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ.
ទស្សនៈដែលមាននៅក្នុងអត្ថបទនេះ មិនមែនជាទស្សនៈរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នករៀបរៀងផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។
Facebook Telegram Website